



# ស្វែងយល់ដឹង អំពី

# តួនាទី ភារកិច្ចរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ









រាល់មាត្រាទាំងឡាយដែលបានបង្ហាញក្នុងការបោះពុម្ពនេះ គឺ ដកស្រង់ទាំងស្រុងពី រដ្ឋធម្មនុញ្ញ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ច្បាប់ និងអនុក្រឹត្យជាធរមាននៅ ព្រះរាជាណាចក្រកម្ពុជា

## សេចក្តីថ្លែងអំណរគុណ

វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ(API) សូមថ្លែងអំណរគុណ ចំពោះបុគ្គលិកទាំងអស់អង្គការដៃគូសហគមន៍អ្នករចនានិងអ្នកកែសម្រួល អត្ថបទដែលបានចំណាយពេលវេលាចូលរួមចែករំលែកនូវគំនិតយោបល់ បទពិសោធន៍និងរូបភាពល្អៗដល់ការរៀបចំចងក្រងសៀវភៅនិងសូម ថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់ដែលបានឧបត្ថម្ភក្នុងការបោះពុម្ពផ្សាយនេះ ។

**ផលិតដោយ**

API BUILDING CAPACITY FOR CHANGE

**ឧបត្ថម្ភដោយ**

DANIDA

FOLKEKIRKENS NØDHJÆLP DAN CHURCH AID

forum syd

icco Grenzeloos betrokken

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១. | សេចក្តីផ្តើម | ១ |
| ២. | សិទ្ធិសំខាន់ៗរបស់យើង | ២ |
| ៣. | ស្ថានភាពគោរពសិទ្ធិនាពេលបច្ចុប្បន្ន | ៩ |
| ៤. | តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | ១០ |
| ៥. | តួនាទី និងភារកិច្ចរបស់ប្រជាពលរដ្ឋ | ១២ |
| ៦. | ផលប្រយោជន៍នៃការអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិ | ១៦ |

# ១–សេចក្តីផ្តើម

ចាប់ពីឆ្នាំ២០០២ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានបោះឆ្នោតឡើងដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលបែបវិមជ្ឈការឱ្យមានប្រសិទ្ធភាពខ្ពស់ហើយជាឱកាសមួយដើម្បីធ្វើឱ្យទំនាក់ទំនងរវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាលកាន់តែជិតស្និទ្ធឡើងថែមទៀតក្នុងគោលបំណងលើកស្ទួយអភិបាលកិច្ចមូលដ្ឋានឱ្យកាន់តែប្រសើរឡើង។

សៀវភៅនេះនឹងជាជំនួយសម្រាប់អាជ្ញាធរមូលដ្ឋាននិងសហគមន៍ដើម្បីសិក្សាស្វែងយល់បន្ថែមទៀតអំពីសិទ្ធិនិងតួនាទីភារកិច្ចសំខាន់ៗរបស់ខ្លួនដើម្បីធ្វើឱ្យមានទំនុកចិត្តនិងជំរុញការប្តេជ្ញាចិត្តបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀតដើម្បីបំពេញការងារឱ្យទទួលបានជោគជ័យ។

# ២–សិទ្ធិសំខាន់ៗរបស់យើង

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិមានអ្វីៗដែលចាំបាច់សម្រាប់ការរស់រានមានជីវិតប្រកបដោយ
សិទ្ធិឱ្យយើងទេហើយក៏គ្មានបុគ្គលណាអាចដកហូតសិទ្ធិពីយើងស្រេចចិត្តបានឡើយព្រោះរដ្ឋធម្មនុញ្ញ
ធម្មនុញ្ញនៃអង្គការសហប្រជាជាតិសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សកតិកាសញ្ញាសន្ធិស
ដូចតទៅនេះ:

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

*(កម្ពុជាបានផ្ដល់សច្ចាប័ននៅឆ្នាំ១៩៩២)*

មាត្រា ១៩. –

ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។ ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មានទទួលនិងផ្សព្វផ្សាយព័ត៌មាននិងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែនដោយផ្ទាល់មាត់សរសេរ ឬបោះពុម្ពតាមទម្រង់សិល្បៈក្តីឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ... ។



## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣៥. –

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។

ត្តិយសនិងសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស។ យើងមានសិទ្ធិតាំងពីកំណើតមកម្ល៉េះគ្មានបុគ្គលណាបង្កើត
នៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់និងធានានូវការគោរពសិទ្ធិមនុស្សនានាដូចមានចែងនៅក្នុង
ញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្សសិទ្ធិស្ត្រីនិងសិទ្ធិកុមារដូចមានចែងក្នុងមាត្រាមួយចំនួន

**មាត្រា ៣៩. –**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារប្តឹងតវ៉ាឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គមនិងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ការដោះស្រាយបណ្តឹងតវ៉ានិងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។



**មាត្រា ៤១. –**

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ... ។

លើសពីនេះទៀត ច្បាប់ និងអនុក្រឹត្យទាំងឡាយខាងក្រោម ក៏បានចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋសហគមន៍មូលដ្ឋានផងដែរ ជាអាទិ៍៖

## អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

( លេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៣ )

មាត្រា ៦. –

សហគមន៍ព្រៃឈើអាចផ្ដួចផ្ដើមនិងសុំបង្កើតឡើងដោយសហគមន៍មូលដ្ឋាន ឬរដ្ឋបាលព្រៃឈើ។ ការបង្កើតសហគមន៍ព្រៃឈើរបស់សហគមន៍មូលដ្ឋានត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមករដ្ឋបាលព្រៃឈើ។








## ច្បាប់ស្តីពីព្រៃឈើ

( ប្រកាសឱ្យប្រើនៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ )

មាត្រា ៤០. –

ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុងឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍រដ្ឋត្រូវទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាននោះសម្រាប់គោលបំណងទំនៀមទម្លាប់ជំនឿសាសនានិងការរស់នៅ...។សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផលអនុផលព្រៃឈើដោយសហគមន៍មូលដ្ឋានមិនតម្រូវឱ្យមានលិខិតអនុញ្ញាតប្រមូលផលឡើយ។សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះរួមមាន :

១. ការរើសប្រមូលឈើងាប់ការបេះផ្លែឈើព្រៃការរុករកឃ្មុំការចោះយកជ័រនិងរុករកអនុផលព្រៃឈើដទៃទៀតទាំងអស់

២. ការប្រើប្រាស់ឈើមកសង់លំនៅដ្ឋានក្រោលសត្វរបងនិងសម្រាប់ធ្វើឧបករណ៍កសិកម្ម

៣. ការច្រូតយកស្មៅ ឬលែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ

៤. ការប្រើប្រាស់ផលអនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណីជាលក្ខណៈគ្រួសារ

៥. សិទ្ធិដោះដូរ ឬលក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាតប្រសិនបើការលក់ដូរនេះ មិនគំរាមកំហែងដល់និរន្តរភាពនៃព្រៃឈើ ...។

# ច្បាប់ស្តីពីជលផល

(ប្រកាសឱ្យប្រើនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០៦)



មាត្រា ៥៩.–

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួនដោយឈរលើគោលការណ៍ស្ម័គ្រចិត្តដើម្បីចូលរួមគ្រប់គ្រងអភិរក្សអភិវឌ្ឍនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។







មាត្រា ៦០. –

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃដែននេសាទឱ្យទៅសហគមន៍ដែលរស់នៅក្នុងឬក្បែរដែននេសាទក្រោមរូបភាពជាកន្លែងនេសាទសហគមន៍ ។





មាត្រា ៦២. –

កន្លែងនេសាទសហគមន៍ត្រូវបានគ្រប់គ្រងដោយធានានិរន្តរភាពដោយសហគមន៍នេសាទ ស្របតាមផែនការ គ្រប់គ្រងកន្លែងនេសាទសហគមន៍វិធានសហគមន៍នេសាទនិងគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។ រដ្ឋបាលជលផលត្រូវផ្តល់ជំនួយបច្ចេកទេសតាមការ ស្នើសុំរបស់សហគមន៍មូលដ្ឋាននិងត្រូវតាមដានត្រួតពិនិត្យការអនុវត្តផែនការ គ្រប់គ្រងកន្លែងនេសាទសហគមន៍ ...។

# ច្បាប់ភូមិបាល

( ប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ )




មាត្រា ៥. –

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់និងនីតិវិធីបញ្ញត្តិដោយច្បាប់និងបទបញ្ជាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌។



មាត្រា ៣០. –

បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ (ប្រាំ) ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ...។

# ៣–ស្ថានភាពគោរពសិទ្ធិនាពេលបច្ចុប្បន្ន

ដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យការគោរពសិទ្ធិមនុស្សនិងការបំពេញកាតព្វកិច្ច របស់រាជរដ្ឋាភិបាលកម្ពុជាបានវិវឌ្ឍរីកចំរើនជាបន្តបន្ទាប់ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជាធម្មនុញ្ញនៃអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្សនិងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្សសិទ្ធិនារី និងសិទ្ធិកុមារ។ ប៉ុន្តែទោះជាយ៉ាងណា ប្រជាពលរដ្ឋខ្មែរនៅតែមិនទាន់បានអនុវត្ ទទួលបានការឆ្លើយតបគ្រប់គ្រាន់ ចំពោះ ជាមូលដ្ឋានសំខាន់ៗនៅឡើយទេ។ ភាពខ្វះ ចន្លោះទាំងនោះមានជាអាទិ៍ ការរំលោភសិ មនុស្ស ការកាប់បំផ្លាញព្រៃឈើដើម្បីទន្ទ្រាន យកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ទំនាស់ដីធ្លីការនេសាទ ខុសច្បាប់...។ អ្នករងគ្រោះភាគច្រើនជាប្រជាជនក្រីក្រ អ្នកគ្មានអំណាច ជាពិសេសសហគមន៍ជនជាតិដើមភាគ





សេរីភាពបញ្ចេញមតិតាមទីសាធារណៈរបស់ប្រជាពលរដ្ឋនៅមានកម្រិត។ ព័ត៌មានសាធារណៈសំខាន់ៗមួយចំនួនដូចជាកិច្ចសន្យាវិនិយោគសាធារណៈ ការដេញថ្លៃ ការចំណាយផ្សេងៗរបស់រដ្ឋ ការកំណត់ថ្លៃសម្រាប់សេវាសាធារណៈនានាមិនទាន់បានផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋនៅឡើយទេ។ ឧទាហរណ៍ការបង់ថ្លៃសេវាធ្វើសំបុត្រកំណើតសំបុត្រអាពាហ៍ពិពាហ៍អត្តសញ្ញាណប័ណ្ណសកម្មភាពនេសាទ ការចុះបញ្ជីដីធ្លី និងសេវាមិនបង់ថ្លៃជាច្រើនទៀតរបស់រដ្ឋនៅតែជាអាថ៌កំបាំងដែលបង្កភាពមន្ទិលដល់ប្រជាពលរដ្ឋហើយតម្រូវឱ្យប្រជាពលរដ្ឋចំណាយក្រៅផ្លូវការលើសពីការកំណត់របស់រដ្ឋដែលជាហេតុបណ្តាលឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតែបន្តញាំញីដោយភាពក្រីក្រ។



# ៤–តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

បន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ២០០២ក្រុមប្រឹក្សាឃុំ–សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាល
សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំសង្កាត់របស់ខ្លួនបម្រើផលប្រយោជន៍រួមរបស់ប្រជា
ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១ មាត្រា ៤២ ៤៣ ៤៤ បានផ្តល់តួនាទី

## ១–តួនាទីបម្រើកិច្ចការមូលដ្ឋាន

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ



បកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានដែលមានប្រកបដោយចីរភាព
ពលរដ្ឋនិងគោរពផលប្រយោជន៍ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។
ចំនួន ២ (ពីរ) ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ជាអាទិ៍:



## ២-តួនាទីជាភ្នាក់ងារតំណាងរដ្ឋ

រដ្ឋបាលឃុំសង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ព្រះរាជក្រឹត្យអនុក្រឹត្យប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។



មាត្រា ៣៣. –

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធានាផ្សព្វផ្សាយព័ត៌មានឱ្យបានទៀងទាត់ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ អំពីបញ្ហាទាំងឡាយស្របតាមសមត្ថកិច្ចរបស់ខ្លួន និងអំពីសេចក្តីសម្រេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

(អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ )

FREEDOM OF INFORMATION

បើកចំហព័ត៌មានសាធារណៈ

# ៥-តួនាទី និងភារកិច្ចរបស់ប្រជាពលរដ្ឋ

(អនុក្រឹត្យលេខ ២២ អនក្រ.បក ស្ដីពីការ ផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួននិងរួមចំណែកក្នុងការកសាងប្រទេសជាតិឱ្យរីកចម្រើនរុងរឿងប្រជាពលរដ្ឋគ្រប់រូបក្នុងមូលដ្ឋានត្រូវមានកាតព្វកិច្ចចូលរួមក្នុងការងារសំខាន់ៗរបស់ឃុំ សង្កាត់ដូចជា :

- ប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្ដាប់កិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែពុំមានសិទ្ធិអនុម័តបានទេ។ (មាត្រា ៣០-១ )
- ប្រជាពលរដ្ឋអាចលើកសំណួរដល់មេឃុំ ចៅសង្កាត់ ឬសមាជិកក្រុមប្រឹក្សា ឃុំសង្កាត់ នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំសង្កាត់ដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ (មាត្រា ៣០-២ )



ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ បំពេញតួនាទី និងភារកិ

ពួកគាត់នៅអាណ

- ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើឬធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬការប្តឹងនោះជាកំហិត។ (មាត្រា៣១-១)
- ចំពោះសំណើឬការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំចៅសង្កាត់មិនអាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំចៅសង្កាត់ត្រូវដាក់ក្នុងរបៀបវារៈអង្គប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ (មាត្រា៣១-៣ )
- មេឃុំចៅសង្កាត់ត្រូវជូនព័ត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ (មាត្រា៣១-៤ )
- ប្រជាពលរដ្ឋមានសិទ្ធិដឹងនូវព័ត៌មានទាំងឡាយដែលទាក់ទងទៅនឹងការងារអភិវឌ្ឍន៍ភូមិ ឃុំ។



ច្ចបានល្អតាមច្បាប់កំណត់ នោះយើងនឹងបោះឆ្នោតគាំទ្រ
ាត្តិក្រោយទៀត !




ចូលរួមធ្វើផែនការ½ ចូលរួមស
ពីបញ្ហាដែលជួបប្រទះក្នុងដំណើកា



ទទួលព័ត៌មានពីស្ថាប័នសាធារណ:½ ប្រជាពលរដ្ឋ
គ្រប់រូបមានសិទ្ធិទទួលនិងស្វែងរកព័ត៌មានដែលទាក់ទង
ទៅនឹងការងារឃុំសង្កាត់និងការងារអភិវឌ្ឍន៍នានា ។
ឧទាហរណ៍ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធដឹងនូវព័ត៌មាន
ពីក្រុមប្រឹក្សាឃុំ សង្កាត់ ទាក់ទងនឹងការដេញថ្លៃ
ផលប្រយោជន៍ និងផលប៉ះពាល់របស់សហគមន៍ និង
ចំណូលចំណាយផ្សេងៗ ។



ផ្តល់ព័ត៌មាន និងយោបល់½ ប្រជាពលរដ្ឋមានសិទ្ធិ
និងតួនាទីផ្តល់នូវព័ត៌មាន និងយោបល់តាមរយៈការចូលរួមប្រជុំ
ក្រុមប្រឹក្សាឃុំ សង្កាត់ និងតាមរយៈការសរសេរជាលិខិតផ្តល់ជាម
យោបល់ដាក់ទៅក្នុងប្រអប់សំបុត្រគណនេយ្យភាពមូលនិធិឃុំសង្កាត់

បើអ្នកចូលរួមក្នុងការងារឃុំ សង្កាត់របស់អ្នកកាន់តែប្រ

ង្កេតការណ៍បញ្ចេញយោបល់និងលើក
កសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។



តាមដាននិងត្រួតពិនិត្យ½ ប្រជាពលរដ្ឋមានតួនាទី តាមដាននិងពិនិត្យមើលនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ តាមយៈការសង្កេតពីលទ្ធផលការងារ ប្រៀបធៀបទៅនឹងផែនការ និងការសន្យាមុនពេលបោះឆ្នោត។

ចូលរួមថែទាំ និង
ការពារធនធានធម្មជាតិ



...។

ច្រើន នោះអ្នកនឹងទទួលបានផលប្រយោជន៍កាន់តែច្រើន !

# ៦. ផលប្រយោជន៍នៃការអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិ

ប្រសិនបើក្រុមប្រឹក្សាឃុំសង្កាត់និងប្រជាពលរដ្ឋទាំងអស់គ្នាបានបំពេញតួនាទីនិងភារកិច្ច តាមមុខការរៀងៗខ្លួននោះ យើងនឹងទទួលបានផលប្រយោជន៍ជាច្រើនដូចជា :

- ទទួលបានព័ត៌មានច្បាស់លាស់ដើម្បីអាចធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវជួយដល់ការរស់នៅនិងការងារប្រចាំថ្ងៃ ដើម្បីអភិវឌ្ឍន៍ទាំងស្មារតី និងសម្ភារ។
- អាចដឹងថាសេវាសាធារណៈណាខ្លះដែលបង់ថ្លៃ និងមិនបង់ថ្លៃ
- អាចតាមដានសំណើនានាដែលស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចដូចជា ការធ្វើអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងលិខិតស្នាមផ្សេងៗ ថាតើដំណើរការដល់ណាហើយ?





- ជំរុញឱ្យប្រ
  ការសម្រេ
- ជួយក្រុមប្រឹ
- បង្កើនទំនុ
- មានការគ





- ធ្វើឱ្យការអនុវត្តផែនការអភិវឌ្ឍន៍ឃុំសង្កាត់ និងផែនការអភិវឌ្ឍន៍ជាតិសម្រេចបានជោគជ័យហើយឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។
- អាចដឹងពីចំណូលនិងចំណាយរបស់ឃុំសង្កាត់សម្រាប់គម្រោងការអ្វីមួយ និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នានា ។ល។

ជាពលរដ្ឋចូលរួមទទួលខុសត្រូវកាន់តែច្រើនឡើងចំពោះគម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួនការងារពាក់ព័ន្ធនឹង
ចចិត្តអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពអភិវឌ្ឍន៍នានា។
បឹក្សាឃុំ សង្កាត់ ក្នុងការប្រើប្រាស់ធនធានដែលមានឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព។
កចិត្ត និងទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធរវាងរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ។
ាំទ្រ និងចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋលើគ្រប់វិស័យ។

យើងរួមគ្នាអនុវត្តសិទ្ធិ តួនាទី និងភារកិ

និងកូនចៅរបស់យើ



ចូ របស់យើង ដើម្បីផលប្រយោជន៍យើង

ើងទៅថ្ងៃអនាគត !



វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកឯករាជ្យមានលក្ខណៈអាជីពនិងមិនស្វែងរកប្រាក់ចំណេញមិនគាំទ្រគណបក្សនយោបាយនិងមិនធ្វើនយោបាយឡើយ។ វិទ្យាស្ថានធ្វើការដើម្បីបម្រើនូវតម្រូវការចាំបាច់ផ្នែកអភិវឌ្ឍន៍សង្គមនិងលទ្ធិប្រជាធិបតេយ្យក្នុងរយៈពេលយូរអង្វែងដោយមានការចូលរួមចំណែកនៅក្នុងវិស័យអភិវឌ្ឍន៍គោលនយោបាយនិងការតស៊ូមតិហើយបាននិងកំពុងអនុវត្តសកម្មភាពរបស់ខ្លួនដោយអនុលោមទៅតាមគោលនយោបាយសហប្រតិបត្តិការអន្តរជាតិនិងនីតិរដ្ឋការពារនិងគោរពច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងគាំទ្រយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅកម្ពុជាឱ្យបានប្រសើរបំផុត។ វិទ្យាស្ថានតាំងចិត្តធ្វើការជាមួយស្ថាប័នជាតិនិងអន្តរជាតិដែលបានចូលរួមចែករំលែកទស្សនៈរបស់ខ្លួនជួយគាំទ្រការផ្លាស់ប្តូរសង្គមឱ្យបានប្រសើរនិងមានសន្តិភាពព្រមទាំងបង្កើនសមត្ថភាពនិងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទាំងអស់។ វិទ្យាស្ថានខិតខំស្វះស្វែងស្ថាបនាចំណងទាក់ទងដើម្បីផ្សារភ្ជាប់រវាងរដ្ឋាភិបាលប្រជាពលរដ្ឋនិងស្ថាប័នឯកជននានា។

API
BUILDING CAPACITY
FOR CHANGE

## វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

## Advocacy and Policy Institute


មជ្ឈមណ្ឌលភ្នំពេញ អាគារ F (ជាន់ទី ៤) បន្ទប់លេខ ៤៨៤ កែងមហាវិថីព្រះសីហនុ និងព្រះសុធារស

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : (+៨៥៥) ២៣ ២១៣ ៤៨៦

ទូរសារ : (+៨៥៥) ២៣ ២១៣ ៤៨៧

វិបសាយ : www.apiinstitute.org